# ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS៖ ឧបករណ៍ពណ៌នាមុខតំណែង

Khmer | ភាសាខ្មែរ

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS (ក្របខ័ណ្ឌ) ពណ៌នាអំពីអាកប្បកិរិយា ជំនាញ និងចំណេះដឹងដែលត្រូវបានរំពឹងទុកពីបុគ្គលិកទាំងអស់ដែលបានទទួលមូលនិធិនៅក្រោម NDIS។ វាផ្តល់នូវឧទាហរណ៍ច្បាស់លាស់ និងជាក់ស្តែងមួយចំនួន ហើយបង្កើតជាភាសារួមអំពី 'អ្វីដែលមើលទៅល្អ' សម្រាប់អ្នកចូលរួមទាំងឡាយដែលកំពុងទទួលសេវា និងការគាំទ្រពី NDIS។ ឧបករណ៍នេះគាំទ្រដោយប្រើក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម។

ឧបករណ៍ពណ៌នាមុខតំណែង គាំទ្រអ្នកចូលរួម NDIS និងអ្នកផ្តល់សេវានានា ដើម្បីបង្កើតការពណ៌នាមុខតំណែង ដោយផ្អែកលើសមត្ថភាពនៅក្នុងក្របខ័ណ្ឌនេះ។ មានសៀវភៅមគ្គុទេសក៍ដែលតម្រូវតាមបុគ្គលជាពិសេសសម្រាប់ក្រុមនីមួយៗ៖ អ្នកចូលរួម និងអ្នកផ្តល់សេវា។

*ការធានាថាអ្នកមានការពណ៌នាមុខតំណែងគ្រប់ជ្រុងជ្រោយ មានលក្ខណៈស៊ីសង្វាក់គ្នា នឹងគាំទ្រទាំងគោលដៅរបស់អ្នកចូលរួម និងអ្នកផ្តល់សេវា ហើយផ្តល់នូវការរំពឹងទុកច្បាស់លាស់ពីបុគ្គលិករបស់អ្នក។*

## អ្វីខ្លះដែលនឹងរំពឹងទុក

ឧបករណ៍នេះគាំទ្រអ្នកចូលរួម NDIS និងអ្នកផ្តល់សេវាដើម្បីបង្កើតការពណ៌នាតំណែងយ៉ាងលម្អិតដែលរួមបញ្ចូលព័ត៌មានសំខាន់ៗទាំងអស់នៃមុខតំណែង ហើយដែលកែតម្រឹមស្របជាមួយនឹងក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម។

- **អភិវឌ្ឍ៖** បង្កើតការពណ៌នាមុខតំណែងដែលលម្អិត និងច្បាស់លាស់លើការរំពឹងទុកនានាពីបុគ្គលិក
- **អភិវឌ្ឍ៖** ប្រើឧបករណ៍អន្តរកម្មដើម្បីបញ្ចូលព័ត៌មានរបស់អ្នក ហើយមើលឧបករណ៍ផ្ទុកសមត្ថភាពដែលពាក់ព័ន្ធនានាដោយស្វ័យប្រវត្តិ
- **កែតម្រឹម៖** កែតម្រឹមការពណ៌នាមុខតំណែងរបស់អ្នកជាមួយនឹងសមត្ថភាពក្របខ័ណ្ឌ និងការរំពឹងទុកផ្នែកអាកប្បកិរិយា
- **លទ្ធផល៖** បង្កើតការពណ៌នាមុខតំណែងដែលរួមបញ្ចូលនូវលក្ខខណ្ឌតម្រូវ និងសមត្ថភាពពាក់ព័ន្ធនានា។

## ឧបករណ៍ក្នុងការអនុវត្ត៖

**អ្នកចូលរួម៖** Jen បានសម្រេចចិត្តជួលបុគ្គលិករបស់នាងដោយផ្ទាល់ជាអ្នកចូលរួមដែលគ្រប់គ្រងដោយខ្លួនឯង។ នាងកំពុងជ្រើសរើសបុគ្គលិកជាលើកដំបូង ហើយមិនប្រាកដទេថាតើត្រូវចាប់ផ្តើមពីណាទេ។ វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់នាងដែលថាបុគ្គលិកដែលនាងជួលយល់ដឹងពីតួនាទីដែលពួកគេនឹងទទួល និងអ្វីខ្លះដែលនាងរំពឹងទុកពីពួកគេ។

Jen ប្រើ **<u>ឧបករណ៍ការពណ៌នាមុខតំណែង</u>** ដើម្បីបង្កើតការពណ៌នាមុខតំណែងដែលពណ៌នាយ៉ាងច្បាស់អំពីតម្រូវការ និងសមត្ថភាពនានាដែលនាងត្រូវការពីបុគ្គលិកគាំទ្រ។ ការនេះជួយនាងនៅពេលនាងសម្ភាសន៍បុគ្គលិកដែលមានសក្តានុពល ដើម្បីឱ្យពួកគេដឹងពីអ្វីដែលនាងរំពឹងទុក និងវាយតម្លៃថាតើពួកគេមានសមត្ថភាពដែលត្រូវការឬអត់។ ការពណ៌នាមុខតំណែងក៏ផ្តល់ការណែនាំសម្រាប់បុគ្គលិករបស់នាងនៅពេលពួកគេចាប់ផ្តើមផងដែរ។

**អ្នកផ្តល់សេវា៖** NDIS Care មិនមានការគាំទ្រផ្នែកធនធានមនុស្សទេ ហើយត្រូវការផ្តល់ឱ្យបុគ្គលិករបស់ពួកគេនូវការពណ៌នាមុខតំណែង ដើម្បីបកស្រាយបំភ្លឺការភាន់ច្រឡំមួយចំនួនអំពីតួនាទីរបស់ពួកគេ។

ពួកគេស្វែងរក **<u>ឧបករណ៍ពណ៌នាមុខតំណែង</u>** ហើយអាចបង្កើតការពណ៌នាមុខតំណែងដាច់ដោយឡែកសម្រាប់បុគ្គលិកគាំទ្រ និងអ្នកដឹកនាំក្រុម។ NDIS Care ធ្វើការជាមួយអ្នកចូលរួមមួយចំនួនរបស់ពួកគេ ដើម្បីរួមបញ្ចូលតម្រូវការជាក់លាក់ដែលបុគ្គលិកត្រូវការដើម្បីគាំទ្រពួកគេ។ ឧបករណ៍លោតបំពេញដោយស្វ័យប្រវត្តិនូវសមត្ថភាពនានាដែលពួកគេជ្រើសរើសចេញពីក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម។ NDIS Care ប្រើប្រាស់ការពណ៌នាមុខតំណែងក្នុងការជ្រើសរើសបុគ្គលិករបស់ពួកគេ និងដើម្បីគាំទ្រដល់កម្លាំងការងាររបស់ពួកគេក្នុងការយល់ដឹងអំពីតួនាទីរបស់ពួកគេ។

NDIS Care ក៏ប្រើប្រាស់ **<u>ធនធានសម្រាប់ការជ្រើសរើសបុគ្គលិក និងការសម្រិតសម្រាំងបុគ្គលិក</u>** ផងដែរ នៅពេលជ្រើសរើសបុគ្គលិកទៅកាន់មុខដំណែង។

## ការចូលប្រើប្រាស់ និងការប្រើប្រាស់ឧបករណ៍

ឧបករណ៍ពណ៌នាមុខតំណែងមាននៅតាមអនឡាញ។ ឧបករណ៍នេះគឺសាមញ្ញ ហើយងាយស្រួលប្រើ។ បើកឧបករណ៍ពណ៌នាមុខតំណែង ជ្រើសរើស 'បង្កើតការពណ៌នាមុខតំណែងរបស់អ្នក' ហើយធ្វើតាមការណែនាំភ្លាមដើម្បីបំពេញការពណ៌នាមុខតំណែងរបស់អ្នក។

**ចូលប្រើឧបករណ៍៖** ឧបករណ៍ពណ៌នាមុខតំណែង | សមត្ថភាពកម្លាំងពលកម្ម NDIS ( ndiscommission.gov.au )

អ្នកអាចបំពេញឧបករណ៍ក្នុងវគ្គតែមួយ ឬទាញយកជាឯកសារ Word នៅពេលដែលបានវាយបញ្ចូលព័ត៌មានណែនាំ។

សម្រាប់ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌ ឬការអនុវត្តរបស់សៀវភៅមគ្គុទ្ទេសក៍នេះ សូមចូលមើលគេហទំព័រ៖ https://workforcecapability.ndiscommission.gov.au/។

ទំនាក់ទំនង៖ contactcentre@ndiscommission.gov.au ឬ 1800 035 554។